សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លាម លិះ**

សាស្ត្រាចារ្យណែនាំ

លោក **រុន្ធ ពណ្ណារិទ្ធ**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# អារម្ភកថា

អត្ថបទកិច្ចការស្រាវជ្រាវប្រធានបទ " មូលហេតុនៃកាលុបចោលអាពាហ៍ពិពាហ៍" ដែលស្ថិតក្នុងដៃមិត្តអ្នកអាន ក៏ដូចលោកសាស្ត្រាចារ្យណែនាំកំពុងពិនិត្យមើលនេះ ខ្ញុំបាទសូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គង និងការខ្វះខាតដែលកើតមានឡើង ដោយហេតុថាខ្ញុំបាទមិនបានធ្វើការសិក្សាស៊ីជំរៅ និងមិនបានបង្ហាញពីទិដ្ឋភាពជាក់ស្ដែងនោះទេ។

ការសរសេរកិច្ចការស្រាវជ្រាវនេះគឺជាកាដកស្រង់ និងសង្ខេបតែតាមក្រមរដ្ឋប្បវេណី និងបញ្ចូលគំនិតបន្តិចបន្តួចដែលធ្លាប់បានសិក្សារៀនសូត្រកន្លងមក។ ម្យ៉ាងទៀតការសរសេរអត្ថបទនេះឡើងគឺខ្ញុំបាទបានអានសៀវភៅ របស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ដែលមានឈ្មោះថានីតិគ្រួសារ។ បន្ថែមពីនេះទៀតដើម្បីឲ្យអ្នកអានមិនមានការយល់ច្រឡំខ្ញុំបាទបានបញ្ចូលមោឃភាពនៃអាពាហ៍ពិពាហ៍នៅចំណុចខ្លះៗទៀត។

ហេតុនេះខ្ញុំបាទសុំទទួលយកនូវគំនិតនៃការរិះគន់ទាំងឡាយណា ក្នុងន័យជួយស្ថាបនានូវកិច្ចការស្រាវជ្រាវមួយនេះធ្វើឲ្យកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀត។ ខ្ញុំបាទក៏សូមអភ័យទោសជាមុននូវរាល់កំហុសដែលអាចកើតមានឡើង ទាំងផ្នែកបច្ចេកទេស និងខ្លឹមសារមួយចំនួននៃអត្ថបទនេះផងដែរ។

ជាចុងបញ្ចប់ខ្ញុំសូមជូនពរដល់មិត្តអ្នកអាន ក៏ដូចសាស្ត្រាចារ្យណែនាំឲ្យជួបតែ សេចក្ដីសុខមានសុខភាពល្អ និងសម្រេចបាននូវជោគជ័យគ្រប់កិច្ចការទាំងឡាយ ហើយដើម្បីលើកស្ទួយដល់កាសិក្សាយល់ដឹងដល់កូនខ្មែរជំនាន់ក្រោយឲ្យទទួលបាននូវចំណេះដឹងប្រកបដោយប្រសិទ្ធិភាព និងភាពកាន់តែប្រសើរឡើងមួយកំរិតទៀត។

# មាតិកា

ចំណងជើង ទំព័រ

**អារម្ភកថា**........................................................................................................i

**សេចក្តីផ្តើម**.......................................................................................................3

**មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍**................................................4

I. កាលុបចោលអាពាហ៍ពិពាហ៍....................................................................4

II. អ្នកដែលមានសិទ្ធិទាមទាលុបចោលអាពាហ៍ពិពាហ៍....................................5

III. ការរលត់សិទ្ធិទាមទាការលុបចោលអាពាហ៍ពិពាហ៍……………………………………..5

VI.មោឃភាពនៃអាពាហ៍ពិពាហ៍...................................................................6

**សេចក្តីសន្និដ្ឋាន**...............................................................................................7

**ឯកសារយោង**

# សេចក្តីផ្តើម

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិករវាងបុរសម្នាក់ និងនារីម្នាក់ដែលប្តេជ្ញាថានឹងរួមរស់ជាមួយគ្នាហើយមិនអាចរំលាយតាមចិត្តរបស់ខ្លួនបាន។ កិច្ចសន្យាអាពាហ៍ពិពាហ៍មិនដូចកិច្ចសន្យាលក់ កិច្ចសន្យាជួល ឬកិច្ចសន្យាខ្ចីនោះទេ។ ដើម្បីរៀបអាពាហ៍ពិពាហ៍បានគឺទាមទានូវលក្ខខ័ណ្ឌគ្រឹះដូចជា ត្រូវមានភេទផ្ទុយគ្នា ត្រូវមានការស្ម័គ្រចិត្ត មានអាយុ១៨ឆ្នាំឡើង និងមិនដែលមានអាពាហ៍ពិពាហ៍ពីមុនដែលមិនទាន់រលាយ មិនតែប៉ុននោះអាពាហ៍ពិពាហ៍ ដែលមានសុពលភាពក៏ត្រូវការ លក្ខខ័ណ្ឌទំរង់ចំនួន៤ទៀតរួមមាន ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការបិទផ្សាយ ការធ្វើកិច្ចសន្យា និងការចុះសំបុត្រអាពាហ៍ពិពាហ៍។ នៅក្នុងលក្ខខណ្ឌអាយុ ច្បាប់បានកំណត់ថាភាគីត្រូវមានអាយុ១៨ឆ្នាំឡើងក៏ប៉ុន្តែករណី ភាគីម្ខាងអាយុ ១៦ឆ្នាំឡើង ពុំទាន់ដល់នីតិភាពនោះអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែមានការយល់ព្រមពីអ្នកអាណាព្យាបាល បើអាណាព្យាបាលម្នាក់ជំទាស់ការយល់ព្រមតែម្នាក់ក៏បានដែរ ក៏អាចរៀបអាពាហ៍ពិពាហ៍បានផងដែរបើអនីតិជននេះទទួលបានអគ្គាធីនភាព។ នៅក្នុងលក្ខខណ្ឌទាក់ទងនឹងការព្រមព្រៀងគឺភាគីត្រូវមានការស្ម័កចិត្តដោយមិនមានការបង្ខំ ការឆបោក ការគំរាម ឬការភាន់ច្រឡំលើមនុស្សឡើយ។ នៅក្នុងក្រមរដ្ឋប្បវេណីក៏មានចែងផងដែរទាក់ទងនិងលក្ខខណ្ឌទំនាក់ទំនងញ្ញាតិរវាងគូភាគី នៅក្នុងនោះគេបានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញ្ញាតិលោហិតផ្ទាល់ ហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញ្ញាតិលោហិតក្នុង៣ថ្នាក់ និងការហាមឃាត់ក្នុងការរៀបអាពាហ៍ពិពាហ៍រវាងញ្ញាតិពន្ធនៃខ្សែផ្ទាល់។

យើងឃើញថាលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ដែលបានរៀបរាប់ខាងលើនេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សំរាប់អនាគត់របស់គូស្វាមីភរិយាដែលត្រូវតែយលដឹង។ ក្នុងការដែលភាគី មិនបានយល់ដឹងនោះគឺជាការធ្វេសប្រហែសដែលអាចនាំអោយភាគីអាចទទួលនៅទណ្ឌកម្មនៃការមិនគោរពលក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍ដែលនាំឲ្យអាពាហ៍ពិពាហ៍នោះអាចមានមោឃភាព ឬនាំអោយមានការលុបចោល។ មោឃភាពនិងការលុបចោលអាពាហ៍ពិពាហ៍មានន័យយ៉ាងណានោះខាងក្រោមនេះគឺជាសិក្សាដូចតទៅ៖

# មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍

## I. ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍មានន័យថាអាពាហ៍ពិពាហ៍ដែលបានចុះសំបុត្ររួចហើយនោះមានលក្ខណៈ មិនត្រឹមត្រូវតាមច្បាប់ដែលអាចនាំឲ្យភាគីលុបចោលបាន។ ការលុបចោលអាពាហ៍ពិពាហ៍ភាពផ្ទុយច្បាប់មានកម្រិតទាបជាងករណីនៃមោឃភាព ដែលមិននាំឲ្យមានអានុភាពប្រតិសកម្ម គឺនាំឲ្យអាពាហ៍ពិពាហ៍ត្រូវមានអានុភាពរហូតដល់ពេលលុបចោល។ យើងឃើញថាការលុបចោលអាពាហ៍ពិពាហ៍គឺមានមូលហេតុធំៗចំនួន២យ៉ាង៖

❖ មូលហេតុដែលមានលក្ខណៈជាប្រយោជន៍សាធារណៈ

គឺជាមូលហេតុដែលបានធ្វើផ្ទុយនឹង មាត្រា៩៤៨ ដល់មាត្រា៩៥០ ដែលក្នុងនោះគឺចែងអំពីលក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍ដែលបានរៀបរាប់ខាងលើ ចំណែកឯមាត្រា៩៥១ និងមាត្រា៩៥២ គឺនិយាយអំពីអាពាហ៍ពិពាហ៍រវាងញាតិក្នុងនោះមានញាតិលោហិតនិងញាតិពន្ធ។ ក្នុងច្បាប់បានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ និងសាខាញាតិលោហិតក្នុងបីថ្នាក់ទោះបីបានបញ្ចប់ទំនាក់ទំនងញាតិនិងគ្នាក៏ដោយ។ ហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងបីថ្នាក់ទោះបីជាបានបញ្ចប់ញាតិពន្ធដោយសារការលែងលះក៏ដោយ។ អាពាហ៍ពិពាហ៍ដែលបានធ្វើក្នុងពេលដែលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីមានន័យថាពេលអាពាហ៍ពិពាហ៍មុនរលាយដោយការលែងលះឬដោយមរណភាពសហព័ទ្ធម្ខាងត្រូវទុករយៈពេល ១២០ថ្ងៃផុតសិនទើបអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ក៏ប៉ុន្តែលក្ខខណ្ឌក្នុងអំឡុងពេលហាមឃាត់អាពាហ៍ពិពាហ៍ថ្មីនេះមិនត្រូវបានហាមឃាត់ករណី នារីមានផ្ទៃពោះ ឬមានការបញ្ជាក់ថាគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត។ ទាំងនេះសុទ្ធតែជាមូលហេតុនៃការលុបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាប្រយោជន៍សាធារណៈ។

❖ មូលហេតុដែលមានលក្ខណៈជាប្រយោជន៍ឯកជន

មូលហេតុដែលមានលក្ខណៈជាប្រយោជន៍ឯកជនគឺមានការគំរាមនិងការឆបោក។ ការគំរាមមានន័យថាការជូនដំណឹងអាក្រក់ទៅភាគីម្ខាងដែលធ្វើឲ្យជននោះមានការភ័យខ្លាចហើយយល់

ព្រមរៀបអាពាហ៍ពិពាហ៍។ ចំណែកការឆបោកគឺជាការបោកប្រាស់ឲ្យជនណាម្នាក់ធ្លាក់ក្នុងការភាន់ច្រឡំ ហើយយល់ព្រមរៀបអាពាហ៍ពិពាហ៍។

## II. អ្នកដែលមានសិទ្ធិទាមទាលុបចោលអាពាហ៍ពិពាហ៍

ជនដែលមានសិទ្ធិទាមទារការលុបចោលអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងតាមរយៈបណ្ដឹងទាមទារលុបចោលអាពាហ៍ពិពាហ៍។ អ្នកដែលមានសិទ្ធិទាមទាការលុបចោលអាពាហ៍ពិពាហ៍នេះ ក៏ត្រូវបែងចែកជាពីដែរដូចជា៖

❖ សម្រាប់មូលហេតុដែលមានលក្ខណៈជាប្រយោជន៍សារធារណៈ

សម្រាប់មូលហេតុដែលមានលក្ខណៈជា ប្រយោជន៍សារធារណៈមានភាគីនីមួយៗ ញាតិសន្តានរបស់ភាគី និងតំណាងអយ្យការ សហព័ទ្ធមុនក៏មានសិទ្ធិសុំលុបចោលក្នុងករណីភាគីម្ខាងមិនទាន់លុបចោលអាពាពិពាហ៍មុនឬ មិនគោរពអំឡុងពេលនៃការហាមឃាត់ការពាហ៍ពិពាហ៍ជាដើម។

❖ មូលហេតុដែលមានលក្ខណៈជាប្រយោជន៍ឯកជន

មូលហេតុនេះមានតែបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោកឬដោយការគំរាមទើបមានសិទ្ធិអាចទាមទាការលុបចោលអាពាយ៍ពិពាហ៍នេះបាន។ បណ្ដឹងទាមទារកាលុបចោលអាពាហ៍ពិពាហ៍ត្រូវអនុឡោមតាមច្បាប់ស្តីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដោយតុលាការសម្រេចចេញជាសាលក្រម។

## III. ការរលត់សិទ្ធិប្ដឹងទាមទារការលុបចោលអាពាហ៍ពិពាហ៍

ករណីបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ហើយនោះអាពាហ៍ពិពាហ៍នេះមិនអាចត្រូវបានលុបចោលទេ ប៉ុន្តែជនដែលមិនទាន់គ្រប់អាយុការអាចទាមទារលុបចោលអាពាហ៍ពិពាហ៍អំឡុងពេល ៣ខែគិតចាប់ពីពេលដែលជននោះបានគ្រប់អាយុ។ បើរយៈពេល១២០ថ្ងៃគិតចាប់ពីអាពាពិពាហ៍មុនត្រូវបានរលាយ ត្រូវបានកន្លងផុតក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីសិទ្ធិទាមទាការលុបចោលនេះនិងត្រូវរលត់ដែរ។ បើអាពាហ៍ពិពាហ៍បាន

ធ្វើឡើងដោយការឆបោក ឬការគំរាម សិទ្ធិទាមទាការលុបចោលអាពាហ៍ពិពាហ៍ត្រូវបានរលត់ ប្រសិនបើអំឡុងពេល ៣ខែ បានកន្លងផុត គិតពីពេលដែលបានរួចខ្លួនពីការគំរាម ឬពីពេលដែលបានរកឃើញការឆបោក។

## VI. មោឃភាពនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ដែលចាត់ទុកថាត្រឹមត្រូវតាមលក្ខណៈច្បាប់គឺអាពាហ៍ពិពាហ៍ដែលបានរៀបរាប់ខាងលើ ក៏ប៉ុន្តែមានអាពាហ៍ពិពាហ៍មួយចំនួនត្រូវទុកជាមោឃៈតាំងពីដំបូងព្រោះភាពផ្ទុយនិងច្បាប់មានកំរិតខ្ពស់ក្នុងករណីដូចជា៖

- ប្រសិនបើអាពាហ៍ពិពាហ៍នោះចុះបញ្ជីនៅពេលដែលសហព័ទ្ធណា ម្នាក់ឆ្កួត ឬមិនដឹងខុសត្រូវ។ តែបើសហព័ទ្ធនោះបានជាស្រួលឡើងវិញហើយ ហេតុដែលនាំអោយទុកជាមោឃៈនោះក៏ត្រូវរលាយទៅវិញដែរ។

- ប្រសិនបើភាគីមិនបានដាក់ពាក្យសុំអាពាពិពាហ៍ ការជូនដំណឹងជាសាធារណៈ មិនបានចុះកិច្ចសន្យាអាពាហ៍ពាហ៍ ឬក៏មិនបានចុះបញ្ជីត្រឹមត្រូវនេះជាមូលហេតុនីតិវិធី។ តែប្រសិនបើគ្រាន់តែមានវិការៈបន្តិចបន្តួចទេមិនអាចមានមោឃៈភាពឡើយ។

- កាលបើសហព័ទ្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវគេបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍។ ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាលប្រសិនបើការប្តឹងនោះមិនធ្វើក្នុងរយៈពេល ៦ខែ គិតពីថ្ងៃដែលគេលែងបង្ខំនោះមក។

- ប្រសិនបើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ទ្ធណាម្នាក់មិនទាន់រលាយ។ ការប្តឹងសុំមោឃភាពនៃ អាពាហ៍ពិពាហ៍ក្រោយមិនអាចធ្វើបានឡើយ បើក្រោយពីថ្ងៃចុះអាពាហ៍ពិពាហ៍ ក្រោយនេះ អាពាហ៍ពិពាហ៍មុនត្រូវបានរលាយ។

- អាពាហ៍ពិពាហ៍រវាងញ្ញាតិលោហិត ឬញាតិពន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ ត្រូវទុកជាមោឃៈ លើកលែងតែករណី សហព័ទ្ធណាមួយស្លាប់ សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ ពិពាហ៍ជាមួយសាខាញ្ញាតិពន្ធ។ ការប្តឹងសុំមោឃៈភាពនៃអាពាហ៍ពិពាហ៍ខាងលើនេះមិន អាចផុតអាជ្ញាយុកាលឡើយ។

# សេចក្ដីសន្និដ្ឋាន

តាមការសិក្សាខាងលើបានបង្ហាញថាការលុបចោលអាពាហ៍ពិពាហ៍នេះគឺវាបានកើតឡើងក្រោយពីពេលរៀបការ។ ការលុបចោលនេះ គឺវាសំខាន់ ដែលបានចែងក្នុងលក្ខខណ្ឌគ្រឹះ រួចម្ដងហើយការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ក៏មានចែងក្នុងច្បាប់រួចហើយដែរ ដូចនេះវាគឺគ្រាន់តែជាទណ្ឌកម្មនៃការមិនគោរពលក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍។ ការលុបចោលអាពាហ៍ពិពាហ៍នេះគឺមិនមានលក្ខណៈធ្ងន់ដូចមោឃភាពទេ ដូចនេះគឺវាមានអានុភាពតែត្រឹមរយៈពេលនៃការលុបចោលមានន័យថាមិនមានអានុភាពប្រតិសកម្មទេ។ បើយើងសង្កេតមើលទិដ្ឋភាពជាក់ស្ដែងនៃសង្គមកម្ពុជាបច្ចុប្បន្នកំរមានអ្នកប្ដឹងសុំលុបចោលអាពាហ៍ពិពាហ៍ណាស់ដោយសាតែការយល់ដឹងខាងផ្លូវច្បាប់របស់ប្រជាជនគឺមានកំរិត ម្យ៉ាងទៀតបណ្ដឹងនេះគឺទាមទាភស្ដុតាងដែលមានលក្ខណៈស្មុកស្មាញ។

ដូចនេះដើម្បីឲ្យមានលុបចោលអាពាហ៍ពិពាហ៍ដែលធានាឲ្យមានតម្លាភាពដល់សង្គមគ្រួសារក្នុងប្រទេសកម្ពុជា គឺទាមទាឲ្យពលរដ្ឋត្រូវយល់ដឹងពីច្បាប់ឲ្យបានច្រើន។

# ឯកសារយោង

១. សៀវភៅនីតិគ្រួសារ លោកសាស្រ្តាចារ្យ រុណ ពណ្ណារិទ្ធិ & លោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត

២.ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧